នៅថ្ងៃទី ២៨ ដល់ ៣១ ខែកក្កដា ឆ្នាំ២០០៨ លោក **ប្រាក់ សេរីវឌ្ឍន៍** និងលោក **ប៊ុល ធីរីតា** បុគ្គលិកសេដាក បានអញ្ជើញទៅចូលរួមនៅក្នុងវេទិកាសន្តិសុខស្បៀងថ្នាក់តំបន់ឆ្នាំ ២០០៨ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាអាស៊ីអាគ្នេយ៍ដើម្បីសន្តិសុខស្បៀង និងជំនួញសមភាពនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ តំណាងអង្គការសង្គមស៊ីវិលនៅអាស៊ីអាគ្នេយ៍ រួមទាំងប្រទេសចិន ឥណ្ឌា និងលេខាធិការដ្ឋានអាស៊ី និងតំណាងក្រសួងកសិកម្មម៉ាឡេស៊ីចូលរួមនៅក្នុងវេទិកានេះ ។ វេទិកានេះធ្វើឡើងក្នុងគោលបំណង:



- បង្កើតនូវអន្តរវេទិកាមួយដើមសន្តិសុខស្បៀង និងអធិបតេយ្យស្បៀង
- ពិភាក្សាអំពីការកើនឡើងនូវភាពងាយរងគ្រោះដល់សន្តិសុខស្បៀង
- ពិភាក្សាអំពីយុទ្ធសាស្ត្រដើម្បីការពារការផ្គត់ផ្គង់ស្បៀងរបស់យើង
- បង្កើននូវទំនាក់ទំនងរវាងអ្នកវិភាគ អ្នកធ្វើគោលនយោបាយ និងអ្នកអនុវត្តន៍សន្តិសុខស្បៀង
- ពង្រឹងភាពជាវិជ្ជមាន ទស្សនៈ និងសំណូមពររបស់អង្គការសង្គមស៊ីវិល អ្នកផលិតស្បៀង សាធារណៈជនទូទៅ និងអ្នកបរិភោគនៅក្នុងដំណើរការធ្វើគោលនយោបាយនៅក្នុងកំឡុងពេលនៃវេទិកា លោក **ប្រាក់ សេរីវឌ្ឍន៍** នាយកប្រតិបត្តិអង្គការ សេដាក ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញនូវប្រធានបទមួយស្តីអំពីគំនិតផ្តួចផ្តើមសហគមន៍ឆ្ពោះទៅកាន់ផលិតកម្មស្បៀង និងការរស់នៅប្រកបដោយនិរន្តរភាព ។

បន្ទាប់មក នៅថ្ងៃទី ៣០ លោកបានអញ្ជើញទៅចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់សិទ្ធិកសិករ និងនៅថ្ងៃទី ៣១ ចូលរួមកិច្ចប្រជុំអភិបាលកិច្ច សន្តិសុខស្បៀង និងជំនួញសមភាព អាស៊ីអាគ្នេយ ។ គួរបញ្ជាក់ថា អង្គការសេដាក ក្នុងនាមអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលបានចូលជាសមាជិក ចាប់តាំងពីឆ្នាំក្រុមប្រឹក្សាអាស៊ីអាគ្នេយ៍ដើម្បីសន្តិសុខស្បៀង និងជំនួញសមភាព ២០០៣។